**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៣ សសរ**

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការដឹកនាំការងារធានាសន្តិសុខសំរាប់ កិច្ចដំណើរការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហម

## <u>រាជរដ្ឋាភិបាលកម្ពុជា</u>

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតអោយមានអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ក្តីអតីតមេដឹកនាំខ្មែរក្រហម
- បានឃើញកិច្ចព្រមព្រៀងស្តីពីការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហម រវាងរាជរដ្ឋាភិបាលកម្ពុជានិង អង្គការសហប្រជាជាតិ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣
- យោងតាមការងារចាំបាច់

## <u>សំរេច</u>

**ប្រការ ១ :** បង្កើតគណៈកម្មការមួយដើម្បីដឹកនាំការងារការពារសន្តិសុខ ធានាសុវត្ថិភាពសំរាប់កិច្ចដំណើរការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហមមានឈ្មោះថា : " គណៈកម្មការការពារអង្គជំនុំជំរះ

វិសាមញ្ញ" ហៅកាត់ថា" គ.ក.អ.វ " ( Extraordinary Chambers Security Commisions ) E.C.S.C ។ គ.ក.អ.វ មានសមាសភាពដូចតទៅ:

១- ឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តមនាយឧត្តមសេនីយ៍ ហុក ឡុងឌី អគ្គស្នងការនគរបាលជាតិ អនុប្រធានអចិន្ត្រៃយ៍

៣-ឯកឧត្តមឧត្តមសេនីយ៍ឯក នៅ សំ នាយសេនាធិការចំរុះកងយោធពលខេមរភូមិន្ទ អនុប្រធាន

៤-ឯកឧត្តមឧត្តមសេនីយ៍ឯក នេត សាវឿន អគ្គស្នងការរងនគរបាលជាតិ អនុប្រធាន

៥-ឯកឧត្តមឧត្តមសេនីយ៍ឯក ម៉ៅ ច័ន្ទតារា អគ្គស្នងការរងនគរបាលជាតិ អនុប្រធាន

៦-ឯកឧត្តម អ៊ុច សារុ អគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

៧-ឯកឧត្តម ម៉ប់ សារិន អភិបាលរងរាជធានីភ្នំពេញ សមាជិក

៨-ឯកឧត្តម ឧត្តមសេនីយ៍ទោ ទន្សេ ពិសេន មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៩-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០-ឯកឧត្តម អភិបាលខេត្ត-ក្រុង ពាក់ព័ន្ធ សមាជិក

**ប្រការ ២ :** គណៈកម្មការការពារអង្គជំនុំជំរះវិសាមញ្ញ (គ.ក.អ.វ) មានភារកិច្ច :

- ជួយរាជរដ្ឋាភិបាល ដើម្បីរៀបចំផែនការ និងត្រៀមលក្ខណៈសម្បត្តិផ្សេងៗ ជុំវិញការងារធានាការពារសន្តិសុខ សុវត្ថិភាពក្នុងកិច្ចដំណើរការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហម ។
- ប្រមូលផ្តុំចាត់ចែងកម្លាំងនគរបាលយុត្តិធម៌ និងកងរាជអាវុធហត្ថដោយប្រើប្រាស់សំភារៈឧបករណ៍ មធ្យោបាយដឹកជញ្ជូនរបស់អង្គភាពដែលមានស្រាប់ គួបផ្សំឧបករណ៍សំភារៈបច្ចេកទេស និងមធ្យោបាយដែលផ្តល់ដោយគំរោង ដើម្បីអនុវត្តកិច្ចប្រតិបត្តិការការពារសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈអោយមានប្រសិទ្ធិភាពខ្ពស់ដល់ដំណើរការរៀបចំអង្គជំនុំជំរះវិសាមញ្ញ ។
- សហការជាមួយតំណាងសន្តិសុខរបស់អង្គការសហប្រជាជាតិ ក្នុងការចាត់ចែងការងារការពារសន្តិសុខ សុវត្ថិភាពកិច្ចដំណើរការជំនុំជំរះក្តីអតីតមេដឹកនាំខ្មែរក្រហមតាំងពីដើមទីរហូតដល់ការងារជំនុំជំរះត្រូវបានបញ្ចប់តាមគោលការណ៍ដែលបានព្រមព្រៀងគ្នា ។

- រៀបចំការបណ្តុះបណ្តាលពិសេស ឬបើកសិក្ខាសាលាដល់ប្រតិបត្តិករ ដែលចាត់អោយបំពេញបេសកកម្មការពារកិច្ចដំណើរការជំនុំជំរះក្តី ដោយធ្វើកិច្ចសហប្រតិបត្តិការ និងក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។
- លើកគំរោងស្តីពីការប្រើប្រាស់មធ្យោបាយ ឧបករណ៍ សំភារៈ ថវិកា និងចំនួនកម្លាំងជាក់ស្តែងដែលចូលរួមក្នុងកិច្ចសហប្រតិបត្តិការ ។
- កសាងបទបញ្ជា និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធដល់លក្ខការណ៍ការពារក្នុងកិច្ចដំណើរការជំនុំជំរះក្តីដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

**ប្រការ ៣ :** **គ.ក.អ.ទ** មានសិទ្ធិ :

- បង្កើតលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅក្នុងទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីជាជំនួយការដឹកនាំបញ្ជា ។
- ប្រើប្រាស់ត្រាក្រសួងមហាផ្ទៃ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។
- រៀបចំតែងតាំងមន្ត្រីបំរើការក្នុងលេខាធិការដ្ឋានដោយមានការឯកភាពយល់ព្រមពីប្រធានក្រសួង ឬស្ថាប័នពាក់ព័ន្ធ ។

**ប្រការ ៤ :** ការរៀបចំ នឹងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានត្រូវបានកំណត់ ដោយសេចក្តីសំរេចរបស់ **គ.ក.អ.ទ** ។ ថវិកាសំរាប់ចំណាយក្នុងកិច្ចដំនើរការការពារអង្គជំនុំវិសាមញ្ញ និងលេខាធិការដ្ឋាន **គ.ក.អ.ទ** ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រុមការងាររាជរដ្ឋាភិបាលសំរាប់ជួយរៀបចំការជំនុំជំរះក្តីមេដឹកនាំខ្មែរក្រហម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ អគ្គនាយករដ្ឋបាល និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ៣ ឆ្នាំ២០០៤

ស ខេង

**កន្លែងទទួល:**

- ទីស្តីការក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ការិយាល័យ អ.ស.ប ប្រចាំកម្ពុជា
- ការិយាល័យ UNDP ប្រចាំកម្ពុជា
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ